Cambodian – 5244.06
April 2011

# ឆ្នាំ 2011 ការមិនបាច់ជួយបង់ថ្លៃ Medi-Cal កម្មវិធីសំរាប់ក្មេងមានភាពពិការ

មានក្មេងភាគច្រើនដែលពិការមានសិទ្ធិទទួល Medi-Cal ដែលមិនចាំបាច់ជួយបង់ថ្លៃក្រោមកម្មវិធី Aged & Disabled Federal Poverty Level (A&D FPL) (កម្មវិធីសំរាប់មនុស្សចាស់ & ភាពពិការរស់នៅក្រោមកំរិតក្រីក្ររបស់រដ្ឋ)។ បើសិនក្មេងនោះភាពមានរស់នៅខ្ពស់ហួសកំរិតប្រាក់ចំណូលអនុញ្ញាត, ក្មេងនោះមិនមានសិទ្ធិទទួលបានទេ។[1] ប្រភពចំណូលទាំងឡាយ ត្រូវតែនៅក្នុងកំរិតដែលមានការអនុញ្ញាតក្រោមកម្មវិធី SSI (អេស អេស អាយ)។ បើសិនជាលោកអ្នកមិនអាចចំណាយបន្ថយ ដើម្បីឲ្យមានសិទ្ធិទទួលកម្មវិធី។

កូនក្មេងដែលមានភាពពិការរស់នៅក្នុងក្រុមគ្រួសារមានលក្ខណដូចតទៅ នឹងមានសិទ្ធិទទួលក្នុងឆ្នាំ 2011 :

ឳពុកម្តាយដែលមានកូនម្នាក់ : មានសិទ្ធិទទួល បើសិនជាប្រាក់ចំណូលមិនទាន់បង់ពន្ធដានៅឡើយ ដែលមានចំនួនមិនលើសពី $3561 ក្នុងមួយខែ។

ឳពុកម្តាយដែលមានកូនពីរនាក់ : មានសិទ្ធិទទួល បើសិនជាប្រាក់ចំណូលមិនទាន់បង់ពន្ធដានៅឡើយ ដែលមានចំនួនមិនលើសពី $3861 ក្នុងមួយខែ។

ឳពុកម្តាយទាំងពីរនាក់ដែលមានកូនម្នាក់ ឬពីរនាក់ : មានសិទ្ធិទទួល បើសិនជាប្រាក់ចំណូលមិនទាន់បង់ពន្ធដានៅឡើយ មានចំនួនមិនលើសពី $4229 ក្នុងមួយខែ។

ឳពុកម្តាយទាំងពីរនាក់ដែលមានកូនបួននាក់ : មានសិទ្ធិទទួល បើសិនជាប្រាក់ចំណូលមិនទាន់បង់ពន្ធដានៅឡើយ ដែលមានចំនួនមិនលើសពី $4879 ក្នុងមួយខែ។

បើសិនជាមានការបង់ថ្លៃធានារ៉ាប់រងសុខភាពសំរាប់អ្នកណាម្នាក់នៅក្នុងគ្រួសារ ហើយប្រាក់ចំណូលនោះជាប្រាក់ចំណូលរកបាន, ជាកំរិតតាមច្បាប់លើទឹកប្រាក់ប្រហែលនឹង កើនឡើងជាពីរដងលើចំនួនចំណាយទាំងឡាយនោះ។

កម្មវិធី Medi-Cal ពិនិត្យបញ្ជាក់មើលក្មេងដែលមានលក្ខណៈសមស្របទៅនិងលក្ខខ័ណ្ឌ SSI លើភាពពិការដែលមានសិទ្ធិទទួលដោយធ្វើតាមបែបបទទាំងនេះ : *ដំបូង,* Medi-Cal នឹងពិនិត្យបញ្ជាក់មើលចំនួនទឹកប្រាក់ចំណូលរកបាន ហើយនិងទឹកប្រាក់ដែលមាននៃគ្រួសារ។ ការកាត់ប្រាក់រួមទាំងការបង់ថ្លៃបង់លើការធានារ៉ាប់រងសំរាប់ក្រុមគ្រួសារ។ *ទីពីរ,* Medi-Cal កាត់ប្រាក់ត្រូវការដែលអនុញ្ញាតសំរាប់សមាជិកគ្រួសារផ្សេងៗដែលមិនមែនជាក្មេងពិការនោះ។ ឧបមាដូចជាក្រុមគ្រួសារមានឳពុកម្តាយទាំងពីរនាក់និងកូនបួននាក់ ឬក្រុមគ្រួសារមានគ្នាទាំងអស់ 6 នាក់, Medi-Cal ប្រហែលជាកាត់ប្រាក់ត្រូវការដែលអនុញ្ញាតសំរាប់ 5 នាក់ ឬ $1259 ។ *ទីបី,* ចំនួនដែលនៅសល់គឺជាចំនួនសន្មត់ថាជារបស់ក្មេង។ *ទីបួន,* បើសិនជាចំនួនដែលនៅសល់មិនលើសពីកំរិតក្រីក្ររបស់រដ្ឋសំរាប់មនុស្សម្នាក់ ($908 ក្នុងឆ្នាំ 2011) បូក $230 (ប្រាក់ចំណូលពិសេសកាត់ចេញសំរាប់បុគ្គលម្នាក់ៗ), ក្មេងនោះ មានសិទ្ធិទទួល។

DHS All-County Letter Nos. 00-57, 00-68, 01-18; Welf. & Inst. Code 14005.40.

---

[1] បើសិនជាប្រាក់ចំណូលគ្រួសារជាប្រាក់ចំណូលរកបាន ហើយលើសលើកំរិតបន្តិច, លោកអ្នកអាចកាត់បន្ថយប្រាក់ចំណូលរបស់លោកអ្នក បើសិនជាមានគំរោងទទួលបាយ ដោយបំរើខ្លួនឯងតាមកន្លែងការងារសំរាប់ថ្លៃបង់ការព្យាបាលដែលមិនសងមកវិញ និងថ្លៃមើលថែរក្សាក្មេង។ ប្រាក់ដែលដាក់នៅគណនីបែបនេះ គឺមិនរាប់ទេ ពីព្រោះលោកអ្នកមិនបានបង់ពន្ធទៅឲ្យ Social Security FICA លើប្រាក់នោះឡើយ។

Cambodian – 5244.06
April 2011

# ការពិនិត្យបញ្ជាក់សិទ្ធិទទួលរបស់ក្មេងក្នុងឆ្នាំ 2011

# តារាងសំរាប់កម្មវិធីមនុស្សចាស់ & ភាពពិការរស់នៅក្រោមកំរិតក្រីក្ររបស់រដ្ឋ

# (Aged & Disabled FPL)

| | | |
|---|---|---|
| ប្រាក់ចំណូលដែលមាន | $________ | |
| តិច $20 ការកាត់ប្រាក់ចំណូលរកបានណាមួយ | (____20.00) | |
| ចំនួនសរុបប្រាក់ដែលមាន | | $________ |
| ប្រាក់ចំណូលរកបានដែលមិនទាន់បង់ពន្ធដានៅឡើយ | $________ | |
| ចំនួនសល់តិច $20 កាត់ចេញ | (________) | |
| តិច $65 ប្រាក់ចំណូលរកបានកាត់ចេញ | (____65.00) | |
| សរុប | $________ | |
| តិច 50% | (________) | |
| ចំនួនសរុបប្រាក់ចំណូលរកបាន | | ________ |
| ចំនួនសរុបប្រាក់ចំណូលរកបាន/ប្រាក់ដែលមាន | | ________ |
| កាត់ចេញថ្លៃបង់ការធានារ៉ាប់រងសុខភាពណាមួយ | | (________) |
| កាត់ចេញប្រាក់ត្រូវការដែលអនុញ្ញាតសំរាប់សមាជិកក្រុមគ្រួសារដែលមិនមែនជាក្មេងពិការ - ឧទាហរណ៍ បើសិនជាមានសមាជិក 4 នាក់នៅក្នុងគ្រួសារជាមួយនិងក្មេងពិការ, ចូរប្រើប្រាក់ត្រូវការដែលអនុញ្ញាតសំរាប់ 3 នាក់ | | (________) |
| បូកប្រាក់ចំណូលរបស់ក្មេង ដូចជាប្រាក់ អេស អេស អាយ ហើយនិងពីរភាគបីនៃប្រាក់ចិញ្ចឹមក្មេងណាមួយ | | ________ |
| ចំនួនប្រាក់នៅសល់ គឺជាចំនួននៃប្រាក់ចំណូលដែលសន្មត់ថាជារបស់ក្មេង : | | $________ |

តើចំនួននោះស្មើ ឬតិចជាង 100% នៃកំរិតភាពក្រីក្ររបស់រដ្ឋសំរាប់មនុស្សម្នាក់ ($908 ក្នុងឆ្នាំ 2011) បូក $230 ការដកហូតពិសេសឬ ? បើសិនជាមែន ក្មេងនោះមានសិទ្ធិ ទទួល។

*ប្រាក់ត្រូវការដែលអនុញ្ញាត :* 1 - $600, 2 - $750, 2 មនុស្សពេញវ័យ - $934, 3 - $934, 4 - $1100, 5 - $1259, 6 - $1417, 7 - $1550, 8 - $1692